ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម ទៅជាឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន» និងកែប្រែពីផ្ទៃដីទំហំ៣៧ ៥០០(បីម៉ឺនប្រាំពីរពាន់ប្រាំរយ)ហិកតា មកផ្ទៃដីទំហំ៦២ ៨៨៣(ប្រាំមួយម៉ឺនពីរពាន់ប្រាំបីរយប៉ែតសិបបី)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន»ខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ៣៧ ៥០០(បីម៉ឺនប្រាំពីរពាន់ប្រាំរយ)ហិកតា ដូចមានចែងក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃដីទំហំ២៥ ៣៨៣(ពីរម៉ឺនប្រាំពាន់បីរយប៉ែតសិបបី)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សានិងការពារសោភណភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន» ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តសៀមរាប ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤.-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

## ផែនទីឧទ្យានជាតិព្រះជ័យវរ្ម័ន_នរោត្តម«ភ្នំគូលែន» ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប






សញ្ញាសម្គាល់

- ចំណុចនិយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:200,000

0 2.5 5 10 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**ឧទ្យានជាតិព្រះជ័យវរ្ម័ន_នរោត្តម«ភ្នំគូលែន»**

មានផ្ទៃដីទំហំ ៦២ ៨៨៣ហិកតា

**ប្រភពទិន្នន័យ**

| | |
|---|---|
| ខ្សែព្រំប្រទល់តំបន់ការពារធម្មជាតិ | : ក្រសួងបរិស្ថាន |
| ព្រំប្រទល់រដ្ឋបាល | : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០២១) |
| រូបភាព | : Google Earth |
| ផលិតដោយ | : នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃក្រសួងបរិស្ថាន |

## ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

## ចំណុចនិយាមកានៃផែនទីឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំត្បែង»

| ID | X | Y |
|---|---|---|
| 1 | 412849 | 1521084 |
| 2 | 414831 | 1520384 |
| 3 | 415620 | 1519310 |
| 4 | 418094 | 1520995 |
| 5 | 418583 | 1518659 |
| 6 | 417423 | 1518792 |
| 7 | 417125 | 1517779 |
| 8 | 415722 | 1515074 |
| 9 | 415097 | 1513754 |
| 10 | 416526 | 1513489 |
| 11 | 417240 | 1515103 |
| 12 | 418576 | 1514746 |
| 13 | 418698 | 1513505 |
| 14 | 417991 | 1511342 |
| 15 | 418809 | 1508974 |
| 16 | 418032 | 1507727 |
| 17 | 418939 | 1506421 |
| 18 | 416435 | 1505192 |
| 19 | 413255 | 1504044 |
| 20 | 417639 | 1502424 |
| 21 | 417641 | 1497279 |
| 22 | 410121 | 1490241 |
| 23 | 407393 | 1490288 |
| 24 | 404340 | 1492020 |
| 25 | 402924 | 1495082 |
| 26 | 401731 | 1497491 |
| 27 | 398462 | 1501602 |
| 28 | 396030 | 1504350 |
| 29 | 393618 | 1506080 |
| 30 | 391530 | 1505122 |
| 31 | 390718 | 1505664 |
| 32 | 391532 | 1508537 |
| 33 | 392609 | 1509622 |
| 34 | 390936 | 1511773 |
| 35 | 386675 | 1511628 |
| 36 | 384178 | 1517100 |
| 37 | 383160 | 1515603 |
| 38 | 382251 | 1515135 |
| 39 | 380695 | 1514563 |
| 40 | 379299 | 1514627 |
| 41 | 379589 | 1516072 |
| 42 | 378227 | 1515429 |
| 43 | 376902 | 1516624 |
| 44 | 375235 | 1517017 |
| 45 | 377481 | 1517159 |
| 46 | 379013 | 1516667 |
| 47 | 379898 | 1516937 |
| 48 | 380093 | 1517937 |
| 49 | 380229 | 1519092 |
| 50 | 379314 | 1519436 |
| 51 | 378853 | 1520887 |
| 52 | 378345 | 1521728 |
| 53 | 377895 | 1522913 |
| 54 | 378065 | 1523817 |
| 55 | 379116 | 1524224 |
| 56 | 380309 | 1523626 |
| 57 | 379860 | 1524673 |
| 58 | 380540 | 1525815 |
| 59 | 381052 | 1524707 |
| 60 | 381802 | 1524634 |
| 61 | 382739 | 1523500 |
| 62 | 383210 | 1523949 |
| 63 | 383888 | 1524875 |
| 64 | 384816 | 1524544 |
| 65 | 385712 | 1524349 |
| 66 | 386850 | 1524227 |
| 67 | 387243 | 1523652 |
| 68 | 387531 | 1522849 |
| 69 | 386835 | 1521773 |
| 70 | 386876 | 1520479 |
| 71 | 388296 | 1520082 |
| 72 | 390990 | 1518000 |
| 73 | 394918 | 1515000 |
| 74 | 395817 | 1512825 |
| 75 | 400183 | 1513177 |
| 76 | 402915 | 1512646 |
| 77 | 403576 | 1511019 |
| 78 | 404555 | 1512447 |
| 79 | 405918 | 1514405 |
| 80 | 412056 | 1513321 |
| 81 | 407347 | 1517170 |
| 82 | 409834 | 1517608 |
| 83 | 409899 | 1518900 |
| 84 | 407207 | 1520862 |
| 85 | 407752 | 1521953 |
| 86 | 410117 | 1522714 |
| 87 | 408591 | 1524018 |
| 88 | 409382 | 1525885 |
| 89 | 410970 | 1525593 |
| 90 | 411833 | 1522519 |
| 91 | 412290 | 1526570 |
| 92 | 413065 | 1523332 |